ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# លទ្ធផលរយៈពេល ២២២ថ្ងៃ នៃការអនុវត្តយុទ្ធនាការ ដោះស្រាយការកកស្ទះសំណុំរឿងនៅតាមសាលាដំបូងរាជធានី ខេត្ត

ក្រសួងយុត្តិធម៌ មានកិត្តិយសសូមជម្រាបជូនដល់សាធារណជនទាំងអស់ ឱ្យបានជ្រាបថា៖ នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ គណៈកម្មការដឹកនាំយុទ្ធនាការដោះស្រាយការកកស្ទះសំណុំរឿងនៅតាមសាលាដំបូងរាជធានី ខេត្ត **(គ.យ.ក.ស.)** បានបើកកិច្ចប្រជុំក្រោមអធិបតីភាព **ឯកឧត្តម កើត រិទ្ធ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌** និងជាប្រធាន **គ.យ.ក.ស.** ដោយមានការចូលរួមពីថ្នាក់ដឹកនាំក្រសួងយុត្តិធម៌, ប្រធានសាលាដំបូង, ព្រះរាជអាជ្ញាអមសាលាដំបូង និងប្រធានលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងពាក់ព័ន្ធមួយចំនួន ដើម្បីពិនិត្យមើលវឌ្ឍនភាព និងលទ្ធផលរយៈពេល ២២២ថ្ងៃ នៃការអនុវត្តយុទ្ធនាការដោះស្រាយការកកស្ទះសំណុំរឿងនៅតាមសាលាដំបូងរាជធានី ខេត្ត។

ជាលទ្ធផលក្នុងរយៈពេល២២២ថ្ងៃនៃការអនុវត្តយុទ្ធនាការនេះ សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី ខេត្តទូទាំងប្រទេស បានដោះស្រាយសំណុំរឿងព្រហ្មទណ្ឌដែលកកស្ទះទាំងដំណាក់កាលអយ្យការ ទាំងដំណាក់កាលស៊ើបសួរ និងទាំងដំណាក់កាលជំនុំជម្រះ មានចំនួនសរុបជាង **៣៥ ១០០ សំណុំរឿង ស្មើនឹង ៨៩%** នៃសំណុំរឿងព្រហ្មទណ្ឌដែលកកស្ទះ (សំណុំរឿងដែលត្រូវបានជំនុំជម្រះរួចមានចំនួនជាង **១២ ២០០ សំណុំរឿង ស្មើនឹង ៩៥%** នៃសំណុំរឿងទាំងអស់ក្នុងដំណាក់កាលជំនុំជម្រះ)។ បន្ថែមពីនេះ សាលាដំបូងរាជធានី ខេត្តទូទាំងប្រទេស ក៏បានដោះស្រាយសំណុំរឿងព្រហ្មទណ្ឌដែលចូលថ្មី ចំនួនជាង **៣៦ ៥០០ សំណុំរឿង ស្មើនឹង ៧៣%** នៃសំណុំរឿងចូលថ្មីសរុប។ ជាមួយនឹងលទ្ធផលនេះ **គ.យ.ក.ស.** ក៏បានប្រកាសអំពីជោគជ័យនៃការអនុវត្តយុទ្ធនាការដល់សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តចំនួន ១០ បន្ថែមទៀត រួមមាន ខេត្តរតនគិរី, ខេត្តមណ្ឌលគិរី, ខេត្តក្រចេះ, ខេត្តកំពង់ចាម, ខេត្តពោធិ៍សាត់, ខេត្តបាត់ដំបង, ខេត្តប៉ៃលិន, ខេត្តឧត្តរមានជ័យ, ខេត្តកំពង់ស្ពឺ និងខេត្តតាកែវ។ គិតមកដល់បច្ចុប្បន្ននេះ សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តសរុបចំនួន ១៥ ហើយក្នុងចំណោមសាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី ខេត្តចំនួន ២៤ បានប្រកាសបញ្ចប់ដោយជោគជ័យនៃការអនុវត្តយុទ្ធនាការនៅក្នុងស្ថាប័នរបស់ខ្លួន ដោយបានសម្រេចដោះស្រាយសំណុំរឿងព្រហ្មទណ្ឌដែលកកស្ទះបានយ៉ាងតិច ៩៥% និងសំណុំរឿងដែលចូលថ្មី យ៉ាងតិច ៧០%។ លទ្ធផលលម្អិត និងសង្ខេបនៃការអនុវត្តយុទ្ធនាការរយៈពេល ២២២ថ្ងៃ មានភ្ជាប់ជាឧបសម្ព័ន្ធនៃសេចក្តីប្រកាសព័ត៌មាននេះ។

តាមការគ្រោងទុក យុទ្ធនាការដោះស្រាយការកកស្ទះសំណុំរឿងនៅតាមសាលាដំបូងរាជធានី ខេត្ត នឹងត្រូវប្រើរយៈពេល ១ឆ្នាំ ដោយចាប់ផ្តើមគិតពីថ្ងៃប្រកាសបើកយុទ្ធនាការ កាលពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២០ និងគ្រោងបញ្ចប់នៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២១។ ផ្អែកលើលទ្ធផលដែលសម្រេចបានរយៈពេល ២២២ថ្ងៃនេះ ជាមួយនឹងការខិតខំប្រឹងប្រែងរបស់សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី ខេត្ត និងដោយមានការគាំទ្រពីគ្រប់តួអង្គពាក់ព័ន្ធទាំងអស់ **គ.យ.ក.ស.** មានក្តីរំពឹងទុកយ៉ាងមុតមាំថា សាលាដំបូង និងអយ្យការអមសាលាដំបូងទូទាំងប្រទេស នឹងអនុវត្តយុទ្ធនាការសម្រេចបានលទ្ធផលជោគជ័យ ដោយធ្វើការដោះស្រាយសំណុំរឿងកកស្ទះទាំងអស់ ហើយឈានទៅដល់ការប្រកាសបិទបញ្ចប់នៃការអនុវត្តយុទ្ធនាការតាមផែនការដែលបានគ្រោងទុក។

ទន្ទឹមនឹងការសម្តែងនូវអំណរសាទរចំពោះសាលាដំបូង និងអយ្យការអមសាលាដំបូងដែលត្រូវបានប្រកាសអំពីជោគជ័យនៃការអនុវត្តយុទ្ធនាការនាពេលនេះ **គ.យ.ក.ស.** ក៏សូមឆ្លៀតឱកាសនៃកិច្ចប្រជុំនេះ សម្តែងការកោតសរសើរ និងវាយតម្លៃខ្ពស់ដល់កិច្ចខិតខំប្រឹងប្រែងរបស់ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី អាជ្ញាសាលា មន្ត្រីរាជការនៃអង្គភាពរដ្ឋបាល

នៃសាលាដំបូង និងអយ្យការអមសាលាដំបូងទាំងអស់ ព្រមទាំងក្រុមការងារនៃ **គ.យ.ក.ស.** ក៏ដូចជាស្ថាប័នពាក់ព័ន្ធ ដែលបានចូលរួមយ៉ាងសកម្មប្រកបដោយឆន្ទៈ និងស្មារតីទទួលខុសត្រូវខ្ពស់ ក្នុងការជំរុញការអនុវត្តយុទ្ធនាការដោះស្រាយការកកស្ទះសំណុំរឿងនៅតាមសាលាដំបូងរាជធានី ខេត្ត ឱ្យសម្រេចបាននូវសមិទ្ធផលមួយល្អប្រសើរគួរជាទីមោទក ប្រកបដោយគុណភាព និងប្រសិទ្ធភាព ធានាបាននូវការអនុវត្តយ៉ាងត្រឹមត្រូវនូវអភិក្រមការងារក្នុងយុទ្ធនាការគឺ **«លឿន ត្រឹមត្រូវ យុត្តិធម៌ និងមិនពុករលួយ»** ដើម្បីជាប្រយោជន៍ដល់ប្រជាពលរដ្ឋ ក៏ដូចជាវិស័យយុត្តិធម៌ផងដែរ។

សេចក្ដីដូចបានជម្រាបជូនខាងលើនេះ សូមសាធារណជនមេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃពុធ ១ រោច ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០

**គណៈកម្មការដឹកនាំយុទ្ធនាការដោះស្រាយការកកស្ទះសំណុំរឿង**

**នៅតាមសាលាដំបូងរាជធានី ខេត្ត** (**គ.យ.ក.ស.**) KR

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងយុត្តិធម៌
លេខាធិការដ្ឋាន គ.យ.ក.ស.

# របាយការណ៍ស្តីពីលទ្ធផលរយៈពេល ២២២ថ្ងៃ នៃការអនុវត្តយុទ្ធនាការដោះស្រាយការកកស្ទះសំណុំរឿងនៅតាមសាលាដំបូងរាជធានី ខេត្ត (ថ្ងៃទី១៨ ខែឧសភា ដល់ ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០)

## ក. សេចក្តីផ្តើម

កាលពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២០ ឯកឧត្តម **កើត រិទ្ធ** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងជាប្រធាន **គ.យ.ក.ស.** បានប្រកាសបើកយុទ្ធនាការដោះស្រាយការកកស្ទះសំណុំរឿងនៅតាមសាលាដំបូងរាជធានី ខេត្ត ដោយមានក្រុមការងារចំនួន ៤ និងលេខាធិការដ្ឋានជាសេនាធិការ។ ក្រុមការងារទាំងអស់បានចាប់ផ្តើមអនុវត្តយុទ្ធនាការនេះជាបន្តបន្ទាប់តាមតំបន់ទទួលខុសត្រូវនៅសាលាដំបូងទូទាំងប្រទេស។ ក្នុងស្មារតី និងឆន្ទៈប្រកបដោយការទទួលខុសត្រូវរបស់ខ្លួន ក្រុមការងារទាំង៤ នៃ **គ.យ.ក.ស.** ដោយមានការគាំទ្របច្ចេកទេស រដ្ឋបាល និងហិរញ្ញវត្ថុរបស់លេខាធិការដ្ឋាន ក្រុមការងារនីមួយៗ បានរៀបចំបែងចែកតួនាទី ភារកិច្ច កម្មវិធីការងារ និងផែនការសកម្មភាពរបស់ខ្លួន ព្រមទាំងបានអនុវត្តយុទ្ធនាការជាបន្តបន្ទាប់ គិតមកដល់ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០នេះ គឺជាថ្ងៃទី២២២ នៃការអនុវត្តយុទ្ធនាការដោះស្រាយការកកស្ទះសំណុំរឿងនៅតាមសាលាដំបូងរាជធានី ខេត្ត ដោយទទួលលទ្ធផលជាផ្លែផ្កា និងសមិទ្ធផលការងារជាច្រើន ដែលមានខ្លឹមសារដូចខាងក្រោម។

## ខ. សមិទ្ធផលដែលសម្រេចបានក្នុងរយៈពេល ២២២ថ្ងៃនៃយុទ្ធនាការ

### ១. អំពីចំណាត់ការសំណុំរឿង

យោងតាមលក្ខខណ្ឌដែលបានកំណត់ដោយ គ.យ.ក.ស. ការប្រកាសអំពីជោគជ័យនៃយុទ្ធនាការនៅតាមសាលាដំបូង និងអយ្យការអមសាលាដំបូងនីមួយៗ ធ្វើឡើងដោយឈរលើមូលដ្ឋាននៃចំណាត់ការដោះស្រាយសំណុំរឿងចាស់ឱ្យបានយ៉ាងតិចចំនួន ៩៥% និងសំណុំរឿងថ្មីចំនួន ៧០% នៃសំណុំរឿងទាំង ៣ដំណាក់កាលបញ្ចូលគ្នា (ដំណាក់កាលអយ្យការ ដំណាក់កាលស៊ើបសួរ និងដំណាក់កាលជំនុំជម្រះ)។

ដោយផ្អែកតាមទិន្នន័យសំណុំរឿង ដែលបានបូកសរុបទូទាំងប្រទេស នៅក្នុងដំណាក់កាលទាំង៣ សម្រាប់រយៈពេល ២២២ថ្ងៃ នៃយុទ្ធនាការ យើងអាចកត់សម្គាល់ឃើញថា សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តចំនួន ៥ ដែលបានប្រកាសជោគជ័យរួចរាល់ ក្នុងរយៈពេល ១៥០ថ្ងៃនៃយុទ្ធនាការគឺ **ខេត្តសៀមរាប ខេត្តកោះកុង ខេត្តកំពត ខេត្តបន្ទាយមានជ័យ និងខេត្តត្បូងឃ្មុំ** ។ គិតត្រឹមរយៈពេល២២២ថ្ងៃ នៃយុទ្ធនាការ មានសាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តចំនួន ១០ បន្ថែមទៀតដែលត្រូវបានប្រកាសជោគជ័យនៃយុទ្ធនាការ រួមមាន **ខេត្តបាត់ដំបង ខេត្តមណ្ឌលគិរី ខេត្តក្រចេះ ខេត្តរតនគិរី ខេត្តពោធិ៍សាត់ ខេត្តតាកែវ ខេត្តកំពង់ស្ពឺ ខេត្តកំពង់ចាម ខេត្តប៉ៃលិន និងខេត្តឧត្តរមានជ័យ។**

<table>
<tr><th rowspan="2">សាលាដំបូង</th><th rowspan="2">ចំនួនសំណុំរឿងចាស់</th><th rowspan="2">ចំនួនសំណុំរឿងថ្មី</th><th rowspan="2">ចំណាត់ការសំណុំរឿងចាស់</th><th rowspan="2">ចំណាត់ការសំណុំរឿងថ្មី</th><th colspan="2">លទ្ធផលជាភាគរយ</th></tr>
<tr><th>សំណុំរឿងចាស់</th><th>សំណុំរឿងថ្មី</th></tr>
<tr><td rowspan="2">សៀមរាប</td><td>1575</td><td>3198</td><td>1558</td><td>2722</td><td>99%</td><td>85%</td></tr>
<tr><td colspan="6">ចៅក្រម ១៣រូប ព្រះរាជអាជ្ញា ៧រូប ក្រឡាបញ្ជីតុលាការ ៣៦រូប និងក្រឡាបញ្ជីអយ្យការ ៩រូប</td></tr>
<tr><td rowspan="2">កោះកុង</td><td>365</td><td>740</td><td>365</td><td>655</td><td>100%</td><td>87%</td></tr>
<tr><td colspan="6">ចៅក្រម ៧រូប ព្រះរាជអាជ្ញា ៣រូប ក្រឡាបញ្ជីតុលាការ ៧រូប និងក្រឡាបញ្ជីអយ្យការ ៣រូប</td></tr>
<tr><td rowspan="2">កំពត</td><td>910</td><td>2176</td><td>890</td><td>1859</td><td>98%</td><td>85%</td></tr>
<tr><td colspan="6">ចៅក្រម ៩រូប ព្រះរាជអាជ្ញា ៣រូប ក្រឡាបញ្ជីតុលាការ ១៣រូប និងក្រឡាបញ្ជីអយ្យការ ៣រូប</td></tr>
<tr><td rowspan="2">បន្ទាយមានជ័យ</td><td>1877</td><td>1714</td><td>1849</td><td>1442</td><td>99%</td><td>82%</td></tr>
<tr><td colspan="6">ចៅក្រម ១០រូប ព្រះរាជអាជ្ញា ៥រូប ក្រឡាបញ្ជីតុលាការ ១៦រូប និងក្រឡាបញ្ជីអយ្យការ ៨រូប</td></tr>
<tr><td rowspan="2">ត្បូងឃ្មុំ</td><td>638</td><td>1384</td><td>638</td><td>1238</td><td>100%</td><td>88%</td></tr>
<tr><td colspan="6">ចៅក្រម ៨រូប ព្រះរាជអាជ្ញា ៤រូប ក្រឡាបញ្ជីតុលាការ ១០រូប និងក្រឡាបញ្ជីអយ្យការ ៤រូប</td></tr>
<tr><td rowspan="2">កំពង់ចាម</td><td>1688</td><td>2052</td><td>1613</td><td>1529</td><td>97%</td><td>72%</td></tr>
<tr><td colspan="6">ចៅក្រម ៩រូប ព្រះរាជអាជ្ញា ៥រូប ក្រឡាបញ្ជីតុលាការ ២២រូប និងក្រឡាបញ្ជីអយ្យការ ៥រូប</td></tr>
<tr><td rowspan="2">រតនគិរី</td><td>772</td><td>1130</td><td>760</td><td>919</td><td>99%</td><td>78%</td></tr>
<tr><td colspan="6">ចៅក្រម ៧រូប ព្រះរាជអាជ្ញា ៤រូប ក្រឡាបញ្ជីតុលាការ ១០រូប និងក្រឡាបញ្ជីអយ្យការ ៧រូប</td></tr>
<tr><td rowspan="2">មណ្ឌលគិរី</td><td>939</td><td>813</td><td>888</td><td>677</td><td>95%</td><td>84%</td></tr>
<tr><td colspan="6">ចៅក្រម ៧រូប ព្រះរាជអាជ្ញា ៤រូប ក្រឡាបញ្ជីតុលាការ ១១រូប និងក្រឡាបញ្ជីអយ្យការ ៤រូប</td></tr>
<tr><td rowspan="2">ក្រចេះ</td><td>2266</td><td>1893</td><td>2155</td><td>1656</td><td>96%</td><td>81%</td></tr>
<tr><td colspan="6">ចៅក្រម ៧រូប ព្រះរាជអាជ្ញា ៥រូប ក្រឡាបញ្ជីតុលាការ ១៤រូប និងក្រឡាបញ្ជីអយ្យការ ៦រូប</td></tr>
<tr><td rowspan="2">ប៉ៃលិន</td><td>350</td><td>493</td><td>336</td><td>360</td><td>97%</td><td>72%</td></tr>
<tr><td colspan="6">ចៅក្រម ៨រូប ព្រះរាជអាជ្ញា ៤រូប ក្រឡាបញ្ជីតុលាការ ៨រូប និងក្រឡាបញ្ជីអយ្យការ ៤រូប</td></tr>
<tr><td rowspan="2">បាត់ដំបង</td><td>1924</td><td>2138</td><td>1885</td><td>1873</td><td>98%</td><td>87%</td></tr>
<tr><td colspan="6">ចៅក្រម ១៤រូប ព្រះរាជអាជ្ញា ៥រូប ក្រឡាបញ្ជីតុលាការ ២៤រូប និងក្រឡាបញ្ជីអយ្យការ ៧រូប</td></tr>
<tr><td rowspan="2">ឧត្តរមានជ័យ</td><td>456</td><td>788</td><td>437</td><td>578</td><td>97%</td><td>71%</td></tr>
<tr><td colspan="6">ចៅក្រម ៧រូប ព្រះរាជអាជ្ញា ៤រូប ក្រឡាបញ្ជីតុលាការ ៧រូប និងក្រឡាបញ្ជីអយ្យការ ៤រូប</td></tr>
<tr><td rowspan="2">ពោធិ៍សាត់</td><td>1120</td><td>1364</td><td>1116</td><td>1047</td><td>100%</td><td>77%</td></tr>
<tr><td colspan="6">ចៅក្រម ៩រូប ព្រះរាជអាជ្ញា ៥រូប ក្រឡាបញ្ជីតុលាការ ១២រូប និងក្រឡាបញ្ជីអយ្យការ ៨រូប</td></tr>
<tr><td rowspan="2">កំពង់ស្ពឺ</td><td>2340</td><td>3511</td><td>2214</td><td>2615</td><td>96%</td><td>75%</td></tr>
<tr><td colspan="6">ចៅក្រម ៨រូប ព្រះរាជអាជ្ញា ៤រូប ក្រឡាបញ្ជីតុលាការ ១៣រូប និងក្រឡាបញ្ជីអយ្យការ ៥រូប</td></tr>
<tr><td rowspan="2">តាកែវ</td><td>1845</td><td>1151</td><td>1723</td><td>919</td><td>95%</td><td>76%</td></tr>
<tr><td colspan="6">ចៅក្រម ៨រូប ព្រះរាជអាជ្ញា ៤រូប ក្រឡាបញ្ជីតុលាការ ១៣រូប និងក្រឡាបញ្ជីអយ្យការ ៥រូប</td></tr>
<tr><td>រាជធានីភ្នំពេញ</td><td>7579</td><td>12416</td><td>6191</td><td>7747</td><td>84%</td><td>61%</td></tr>
</table>

| | | | | | | |
|---|---|---|---|---|---|---|
| | ចៅក្រម ៤១រូប ព្រះរាជអាជ្ញា ១៨រូប ក្រឡាបញ្ជីតុលាការ ១៥០រូប និងក្រឡាបញ្ជីអយ្យការ ៥០រូប | | | | | |
| កណ្ដាល | 2724 | 3351 | 1963 | 2234 | 83% | 63% |
| | ចៅក្រម ១៤រូប ព្រះរាជអាជ្ញា ១០រូប ក្រឡាបញ្ជីតុលាការ ៤២រូប និងក្រឡាបញ្ជីអយ្យការ ១១រូប | | | | | |
| ព្រៃវែង | 1390 | 1278 | 1044 | 841 | 87% | 62% |
| | ចៅក្រម ៧រូប ព្រះរាជអាជ្ញា ៤រូប ក្រឡាបញ្ជីតុលាការ ១៥រូប និងក្រឡាបញ្ជីអយ្យការ ៤រូប | | | | | |
| ស្វាយរៀង | 717 | 824 | 662 | 547 | 95% | 64% |
| | ចៅក្រម ៩រូប ព្រះរាជអាជ្ញា ៤រូប ក្រឡាបញ្ជីតុលាការ ៧រូប និងក្រឡាបញ្ជីអយ្យការ ៣រូប | | | | | |
| កំពង់ធំ | 2838 | 2348 | 2641 | 1547 | 94% | 71% |
| | ចៅក្រម ១១រូប ព្រះរាជអាជ្ញា ៣រូប ក្រឡាបញ្ជីតុលាការ ១៧រូប និងក្រឡាបញ្ជីអយ្យការ ៨រូប | | | | | |
| ស្ទឹងត្រែង | 683 | 669 | 641 | 456 | 96% | 64% |
| | ចៅក្រម ៦រូប ព្រះរាជអាជ្ញា ៤រូប ក្រឡាបញ្ជីតុលាការ ៩រូប និងក្រឡាបញ្ជីអយ្យការ ៤រូប | | | | | |
| ព្រះវិហារ | 878 | 866 | 787 | 644 | 92% | 73% |
| | ចៅក្រម ៧រូប ព្រះរាជអាជ្ញា ៤រូប ក្រឡាបញ្ជីតុលាការ ១០រូប និងក្រឡាបញ្ជីអយ្យការ ៦រូប | | | | | |
| កំពង់ឆ្នាំង | 1967 | 1658 | 1726 | 1125 | 92% | 67% |
| | ចៅក្រម ៧រូប ព្រះរាជអាជ្ញា ៤រូប ក្រឡាបញ្ជីតុលាការ ១១រូប និងក្រឡាបញ្ជីអយ្យការ ៧រូប | | | | | |
| ព្រះសីហនុ | 1527 | 1877 | 1041 | 1319 | 74% | 70% |
| | ចៅក្រម ៩រូប ព្រះរាជអាជ្ញា ៥រូប ក្រឡាបញ្ជីតុលាការ ១៦រូប និងក្រឡាបញ្ជីអយ្យការ ៥រូប | | | | | |

ចំនួនចំណាត់ការសំណុំរឿងទូទាំងប្រទេស ទាំង ៣ ដំណាក់កាល




ភាគរយនៃចំណាត់ការសំណុំរឿងទូទាំងប្រទេស ទាំង ៣ ដំណាក់កាល
កោះកុង 87% 100%
កំពត 85% 98%
តាកែវ 76% 95%
ព្រះសីហនុ 70% 74%
កំពង់ស្ពឺ 75% 96%
ពោធិ៍សាត់ 77% 100%
ឧត្តរមានជ័យ 71% 97%
បាត់ដំបង 87% 98%
ប៉ៃលិន 72% 97%
កំពង់ឆ្នាំង 67% 92%
សៀមរាប 85% 99%
បន្ទាយមានជ័យ 82% 99%
ព្រះវិហារ 73% 92%
ត្បូងឃ្មុំ 88% 100%
ស្ទឹងត្រែង 64% 96%
ក្រចេះ 81% 96%
មណ្ឌលគិរី 84% 95%
រតនគិរី 78% 99%
កំពង់ចាម 72% 97%
កំពង់ធំ 71% 94%
ស្វាយរៀង 64% 95%
ព្រៃវែង 62% 87%
កណ្ដាល 63% 83%
រាជធានីភ្នំពេញ 61% 84%
0%
20%
40%
60%
80%
100%
120%
ភាគរយសំណុំរឿងថ្មី ៣ ដំណាក់កាល
ភាគរយសំណុំរឿងចាស់ ៣ ដំណាក់កាល

## ២. ចំណាត់ការដែលបានអនុវត្តតាមសេចក្តីណែនាំរបស់ គ.យ.ក.ស.

យោងតាមសេចក្តីណែនាំលេខ ០១ កយ.សណន/២០ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២០ បានជម្រុញ និងលើកទឹកចិត្តដល់សាលាដំបូង និងអយ្យការអមសាលាដំបូងទូទាំងប្រទេសឱ្យពិចារណាប្រើប្រាស់នីតិវិធីព្រហ្មទណ្ឌមួយចំនួន ដើម្បីចូលរួមចំណែកក្នុងការកាត់បន្ថយភាពចង្អៀតណែននៅក្នុងពន្ធនាគារ រួមមាន៖ ការបង្គាញខ្លួនភ្លាម (CI) ការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ (CD) ការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ការព្យួរទោសធម្មតា និងការព្យួរទោសសាកល្បង។ ជាលទ្ធផល សាលាដំបូង និងអយ្យការអមសាលាដំបូងទូទាំងប្រទេសបានអនុវត្តតាមសេចក្តីណែនាំនេះដូចខាងក្រោម៖

- ការបង្គាញខ្លួនភ្លាម (CI) សរុបចំនួន៖ **<u>៩៤៥សំណុំរឿង/១.០៣២នាក់</u>**
- ការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ (CD) សរុបចំនួន៖ **<u>១.៣៣៣សំណុំរឿង/៩៩៧នាក់</u>**
- ការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ សរុបចំនួន៖ **<u>២.៦០៧សំណុំរឿង/៣.៤៣២នាក់</u>**
- ការព្យួរទោសសាកល្បង សរុបចំនួន៖ **<u>៨១៣សំណុំរឿង/១.១៦៤នាក់</u>**
- ការព្យួរទោសធម្មតា សរុបចំនួន៖ **<u>៤.២២១សំណុំរឿង/៤.៥១៨នាក់</u>**

| រាជធានី ខេត្ត | ដំណាក់កាលអយ្យការ | | | | ដំណាក់កាលស៊ើបសួរ | | ដំណាក់កាលជំនុំជម្រះ | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | ប្រភេទចំណាត់ការ (នៃសំណុំរឿងចាស់និងថ្មី) | | | | ការដាក់ត្រួតពិនិត្យតាមផ្លូវតុលាការ | | ប្រភេទសេចក្ដីសម្រេច | | | | |
| | តម្កល់ទុកឥតចាត់ការ | និតិវិធីបង្ហាញខ្លួនភ្លាម (CI) | បញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ (CD) | ដីកាសន្និដ្ឋានបញ្ជូនសំណុំរឿងទៅស៊ើបសួរ (RI) | សំណុំរឿងសម្រេចមិនឃុំខ្លួន | សំណុំរឿងសម្រេចដោះលែងឱ្យនៅក្រៅឃុំបណ្ដោះអាសន្ន | ព្យួរទោសធម្មតា | ព្យួរទោសសាកល្បង | ផ្ដន្ទាទោសដាក់ពន្ធនាគារ | រួចផុតពីបទចោទ | |
| រាជធានីភ្នំពេញ | 1252 | 216 | 113 | 3378 | 552 | 181 | 525 | 457 | 2425 | 324 | សំណុំរឿង |
| | 1711 | 248 | 154 | 4475 | 554 | 187 | 265 | 649 | 3496 | 398 | ចំនួនមនុស្ស |
| កណ្ដាល | 287 | 234 | 148 | 733 | 3 | 12 | 274 | 38 | 1065 | 27 | សំណុំរឿង |
| | 565 | 323 | 232 | 1447 | 4 | 17 | 471 | 63 | 1752 | 48 | ចំនួនមនុស្ស |
| ព្រៃវែង | 159 | 14 | 41 | 263 | 159 | 17 | 128 | 12 | 499 | 89 | សំណុំរឿង |
| | 126 | 18 | 55 | 381 | 255 | 26 | 295 | 24 | 653 | 147 | ចំនួនមនុស្ស |
| ស្វាយរៀង | 245 | 21 | 34 | 234 | 45 | 35 | 87 | 17 | 169 | 20 | សំណុំរឿង |
| | 246 | 27 | 41 | 317 | 93 | 44 | 139 | 20 | 293 | 32 | ចំនួនមនុស្ស |
| កំពង់ធំ | 260 | 2 | 45 | 480 | 74 | 35 | 227 | 20 | 470 | 68 | សំណុំរឿង |
| | 0 | 0 | 1 | 229 | 78 | 38 | 1 | 0 | 103 | 0 | ចំនួនមនុស្ស |
| កំពង់ចាម | 263 | 35 | 25 | 495 | 63 | 45 | 325 | 26 | 1004 | 34 | សំណុំរឿង |
| | 647 | 50 | 46 | 1112 | 100 | 67 | 51 | 33 | 414 | 10 | ចំនួនមនុស្ស |
| រតនគិរី | 108 | 2 | 83 | 206 | 111 | 6 | 61 | 13 | 482 | 50 | សំណុំរឿង |
| | 161 | 4 | 78 | 342 | 191 | 26 | 88 | 38 | 731 | 65 | ចំនួនមនុស្ស |
| មណ្ឌលគិរី | 139 | 0 | 22 | 257 | 22 | 13 | 86 | 0 | 135 | 27 | សំណុំរឿង |
| | 253 | 0 | 10 | 266 | 28 | 16 | 180 | 0 | 180 | 29 | ចំនួនមនុស្ស |
| ក្រចេះ | 256 | 82 | 151 | 195 | 15 | 2 | 119 | 16 | 635 | 29 | សំណុំរឿង |
| | 0 | 0 | 0 | 0 | 23 | 5 | 0 | 0 | 251 | 3 | ចំនួនមនុស្ស |
| ស្ទឹងត្រែង | 50 | 2 | 14 | 139 | 13 | 19 | 34 | 1 | 354 | 36 | សំណុំរឿង |
| | 54 | 2 | 13 | 181 | 24 | 27 | 53 | 1 | 520 | 51 | ចំនួនមនុស្ស |
| ត្បូងឃ្មុំ | 98 | 1 | 27 | 372 | 70 | 16 | 127 | 0 | 514 | 68 | សំណុំរឿង |
| | 0 | 0 | 0 | 366 | 123 | 16 | 9 | 0 | 440 | 5 | ចំនួនមនុស្ស |
| ព្រះវិហារ | 98 | 1 | 35 | 247 | 66 | 29 | 63 | 4 | 92 | 51 | សំណុំរឿង |
| | 0 | 1 | 7 | 128 | 73 | 45 | 10 | 7 | 87 | 18 | ចំនួនមនុស្ស |
| បន្ទាយមានជ័យ | 730 | 41 | 47 | 430 | 16 | 7 | 78 | 19 | 477 | 36 | សំណុំរឿង |
| | 1269 | 42 | 49 | 670 | 23 | 13 | 167 | 35 | 751 | 84 | ចំនួនមនុស្ស |
| សៀមរាប | 230 | 20 | 44 | 831 | 127 | 53 | 66 | 5 | 1449 | 47 | សំណុំរឿង |
| | 324 | 27 | 56 | 1527 | 246 | 87 | 146 | 9 | 2718 | 108 | ចំនួនមនុស្ស |
| កំពង់ឆ្នាំង | 162 | 13 | 45 | 377 | 112 | 16 | 395 | 3 | 491 | 130 | សំណុំរឿង |
| | 0 | 0 | 0 | 0 | 6 | 21 | 60 | 0 | 194 | 1 | ចំនួនមនុស្ស |
| ប៉ៃលិន | 63 | 0 | 5 | 122 | 22 | 2 | 83 | 10 | 120 | 22 | សំណុំរឿង |
| | 107 | 0 | 8 | 237 | 30 | 8 | 147 | 24 | 184 | 39 | ចំនួនមនុស្ស |
| បាត់ដំបង | 543 | 55 | 71 | 675 | 78 | 30 | 106 | 2 | 1128 | 66 | សំណុំរឿង |
| | 850 | 66 | 103 | 1048 | 116 | 47 | 197 | 5 | 1949 | 162 | ចំនួនមនុស្ស |
| ឧត្ដរមានជ័យ | 122 | 15 | 37 | 162 | 75 | 11 | 119 | 1 | 179 | 25 | សំណុំរឿង |
| | 248 | 26 | 41 | 317 | 119 | 17 | 250 | 3 | 266 | 41 | ចំនួនមនុស្ស |
| ពោធិ៍សាត់ | 156 | 14 | 9 | 228 | 23 | 14 | 88 | 9 | 735 | 76 | សំណុំរឿង |
| | 187 | 12 | 10 | 316 | 29 | 16 | 133 | 0 | 1064 | 92 | ចំនួនមនុស្ស |
| កំពង់ស្ពឺ | 188 | 32 | 43 | 678 | 167 | 29 | 652 | 14 | 706 | 35 | សំណុំរឿង |
| | 2 | 33 | 4 | 741 | 274 | 36 | 834 | 22 | 802 | 19 | ចំនួនមនុស្ស |
| ព្រះសីហនុ | 212 | 21 | 29 | 568 | 7 | 11 | 29 | 4 | 715 | 11 | សំណុំរឿង |
| | 0 | 0 | 0 | 0 | 9 | 8 | 50 | 8 | 1549 | 26 | ចំនួនមនុស្ស |
| តាកែវ | 65 | 76 | 71 | 234 | 61 | 5 | 234 | 109 | 613 | 29 | សំណុំរឿង |
| | 0 | 95 | 0 | 278 | 87 | 7 | 410 | 155 | 997 | 38 | ចំនួនមនុស្ស |
| កំពត | 213 | 46 | 82 | 527 | 48 | 36 | 235 | 31 | 527 | 56 | សំណុំរឿង |
| | 254 | 56 | 87 | 679 | 55 | 20 | 410 | 65 | 827 | 91 | ចំនួនមនុស្ស |
| កោះកុង | 54 | 2 | 112 | 198 | 33 | 21 | 80 | 3 | 174 | 119 | សំណុំរឿង |
| | 0 | 2 | 2 | 183 | 68 | 30 | 152 | 3 | 289 | 122 | ចំនួនមនុស្ស |
| សរុប | 5953 | 945 | 1333 | 12029 | 1862 | 645 | 4221 | 813 | 15158 | 1475 | សំណុំរឿង |
| | 7004 | 1032 | 897 | 15240 | 2608 | 824 | 4518 | 1164 | 20510 | 1619 | ចំនួនមនុស្ស |


ចំនួនសំណុំរឿងដែលបានប្រើនីតិវិធីបង្ហាញខ្លួនភ្លាម (CI)
កណ្ដាល 234
រាជធានីភ្នំពេញ 216
ក្រចេះ 82
តាកែវ 76
បាត់ដំបង 55
កំពត 46
បន្ទាយមានជ័យ 41
កំពង់ចាម 35
កំពង់ស្ពឺ 32
ព្រះសីហនុ 21
ស្វាយរៀង 21
សៀមរាប 20
ឧត្ដរមានជ័យ 15
ពោធិ៍សាត់ 14
ព្រៃវែង 14
កំពង់ឆ្នាំង 13
កោះកុង 2
ស្ទឹងត្រែង 2
រតនគិរី 2
កំពង់ធំ 2
ព្រះវិហារ 1
ត្បូងឃ្មុំ 1
ប៉ៃលិន 0
មណ្ឌលគិរី 0
0
50
100
150
200
250
300

ចំនួនសំណុំរឿងដែលបានប្រើនីតិវិធីបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ (CD)




ចំនួនសំណុំរឿងដែលដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ
រាជធានីភ្នំពេញ 3378
សៀមរាប 831
កណ្ដាល 733
កំពង់ស្ពឺ 678
បាត់ដំបង 675
ព្រះសីហនុ 568
កំពត 527
កំពង់ចាម 495
កំពង់ធំ 480
បន្ទាយមានជ័យ 430
កំពង់ឆ្នាំង 377
ត្បូងឃ្មុំ 372
តាកែវ 334
ព្រៃវែង 263
មណ្ឌលគិរី 257
ព្រះវិហារ 247
ស្វាយរៀង 234
ពោធិ៍សាត់ 228
រតនគិរី 206
កោះកុង 198
ក្រចេះ 195
ឧត្ដរមានជ័យ 162
ស្ទឹងត្រែង 139
ប៉ៃលិន 122
0
500
1000
1500
2000
2500
3000
3500
4000


ព្យួរទោសសាកល្បង
កោះកុង 3 3
កំពត 65 31
តាកែវ 155 108
ព្រះសីហនុ 8 4
កំពង់ស្ពឺ 22 14
ពោធិ៍សាត់ 0 9
ឧត្តរមានជ័យ 3 1
បាត់ដំបង 5 2
ប៉ៃលិន 24 10
កំពង់ឆ្នាំង 0 3
សៀមរាប 9 5
បន្ទាយមានជ័យ 35 19
ព្រះវិហារ 7 4
ត្បូងឃ្មុំ 0 0
ស្ទឹងត្រែង 1 1
ក្រចេះ 0 16
មណ្ឌលគិរី 0 0
រតនគិរី 38 13
កំពង់ចាម 33 26
កំពង់ធំ 0 20
ស្វាយរៀង 20 17
ព្រៃវែង 24 12
កណ្តាល 63 38
រាជធានីភ្នំពេញ 649 457
0 100 200 300 400 500 600 700
មនុស្ស
សំណុំរឿង


ព្យួរទោសជម្មតា
កោះកុង 152 80
កំពត 410 235
តាកែវ 410 234
ព្រះសីហនុ 50 29
កំពង់ស្ពឺ 834 652
ពោធិ៍សាត់ 133 88
ឧត្តរមានជ័យ 250 119
បាត់ដំបង 197 106
ប៉ៃលិន 147 83
កំពង់ឆ្នាំង 60 395
សៀមរាប 146 66
បន្ទាយមានជ័យ 167 78
ព្រះវិហារ 10 63
ត្បូងឃ្មុំ 9 127
ស្ទឹងត្រែង 53 34
ក្រចេះ 0 119
មណ្ឌលគិរី 180 86
រតនគិរី 88 61
កំពង់ចាម 51 325
កំពង់ធំ 1 227
ស្វាយរៀង 139 87
ព្រៃវែង 295 128
កណ្ដាល 471 274
រាជធានីភ្នំពេញ 265 525
0 100 200 300 400 500 600 700 800 900
មនុស្ស សំណុំរឿង

## ៣. ចំនួនបុគ្គលដែលអាចត្រូវបានដោះលែង និងចំនួនបុគ្គលដែលត្រូវបានសម្រេចមិនឃុំខ្លួន

បន្ថែមពីលើការអនុវត្តតាមសេចក្តីណែនាំលេខ០១ខាងលើ មាននីតិវិធីព្រហ្មទណ្ឌមួយចំនួនដែលអាចជួយកាត់បន្ថយនូវការចង្អៀតណែននៅក្នុងពន្ធនាគារ ដូចជា៖ -ការសម្រេចមិនឃុំខ្លួនបណ្តោះអាសន្ន ហើយមិនដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ, -ការចេញដីកាដំណោះស្រាយលើកលែងចោទប្រកាន់, -ការសម្រេចសេចក្តីឱ្យរួចផុតពីបទចោទ, -ការព្យួរទោសធម្មតា, -ការព្យួរទោសសាកល្បង និង -ការដោះលែងទណ្ឌិតដែលអនុវត្តទោសចប់ ។

យោងតាមការស្រង់ទិន្នន័យ និងបូកសរុបរបាយការណ៍របស់តុលាការទូទាំងប្រទេស នៅក្នុងរយៈពេល ២២២ថ្ងៃនៃយុទ្ធនាការនេះ ការចង្អៀតណែននៅក្នុងពន្ធនាគារត្រូវបានកាត់បន្ថយតាមរយៈ៖

- ចំនួនបុគ្គលដែលបានដោះលែងចេញពីពន្ធនាគារចំនួនប្រមាណ <u>១១.២០០នាក់</u>
- ចំនួនបុគ្គលនឹងត្រូវដោះលែងចំនួនប្រមាណ **<u>៥.៦០០នាក់</u>**
- ចំនួនបុគ្គលដែលត្រូវបានសម្រេចមិនឃុំខ្លួនចំនួនប្រមាណ <u>៣.០០០នាក់</u>
- ចំនួនបុគ្គលដែលត្រូវបានបញ្ជូនទៅមណ្ឌលបន្សាបគ្រឿងញៀនជំនួសឱ្យការចោទប្រកាន់ និងបញ្ជូនទៅមណ្ឌលបន្សាបគ្រឿងញៀនដោយសមត្ថកិច្ច មានចំនួនប្រមាណ <u>៦.៣០០នាក់</u> ។

**ជាសរុប នៅក្នុងរយៈពេល ២២២ថ្ងៃ នៃយុទ្ធនាការដោះស្រាយការកកស្ទះសំណុំរឿងនៅតាមសាលាដំបូងរាជធានី ខេត្ត បានចូលរួមចំណែកក្នុងការកាត់បន្ថយភាពចង្អៀតណែន នូវបុគ្គលសរុបចំនួនប្រមាណ <u>២៦.១០០នាក់</u>។**

| រាជធានី ខេត្ត | ចំនួនបុគ្គលដែលបានដោះលែងចេញពីពន្ធនាគារ | | | | | បុគ្គលនឹងត្រូវដោះលែង | | | ចំនួនបុគ្គលដែលត្រូវបានសម្រេចមិនឃុំ | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | លើកលែងទោសប្រកាន់ | សម្រេចដោះលែងឲ្យនៅក្រៅឃុំបណ្ដោះអាសន្ន | រួចផុតពីបទទោស | ទណ្ឌិតអនុវត្តទោសចប់ | សរុបរួម (I) | ព្យួរទោសធម្មតា | ព្យួរទោសសាកល្បង | សរុប (II) | សម្រេចមិនឃុំ(ប៉ុន្តែស្ថិតក្នុងការត្រួតពិនិត្យតាមផ្លូវតុលាការ) | សម្រេចមិនឃុំ(និងមិនដាក់ស្ថិតក្នុងការត្រួតពិនិត្យតាមផ្លូវតុលាការ) | សរុបរួម (III) |
| | A | B | C | D | I=A+B+C+D | E | F | II=E+F | G | H | III=G+H |
| រាជធានីភ្នំពេញ | 323 | 187 | 388 | 4168 | **5066** | 265 | 649 | **914** | 554 | 12 | **566** |
| កណ្ដាល | 107 | 17 | 48 | 988 | **1160** | 471 | 63 | **534** | 4 | 2 | **6** |
| ព្រៃវែង | 230 | 26 | 147 | 92 | **495** | 295 | 24 | **319** | 255 | 194 | **449** |
| ស្វាយរៀង | 85 | 44 | 32 | 247 | **408** | 139 | 20 | **159** | 93 | 14 | **107** |
| កំពង់ធំ | 13 | ៣៨ | 0 | 0 | **51** | 1 | 0 | **1** | 78 | 8 | **86** |
| កំពង់ចាម | 7 | 67 | 10 | 76 | **160** | 51 | 33 | **84** | 100 | 3 | **103** |
| រតនគិរី | 103 | 26 | 65 | 0 | **194** | 88 | 38 | **126** | 191 | 27 | **218** |
| មណ្ឌលគិរី | 79 | 16 | 29 | 0 | **124** | 180 | 0 | **180** | 28 | 2 | **30** |
| ក្រចេះ | ២ | 5 | 3 | 0 | **10** | 0 | 0 | **0** | 0 | 0 | **0** |
| ស្ទឹងត្រែង | 51 | 27 | 51 | 0 | **129** | 53 | 1 | **54** | 24 | 0 | **24** |
| ត្បូងឃ្មុំ | 3 | 16 | 5 | 0 | **24** | 9 | 0 | **9** | 123 | 3 | **126** |
| ព្រះវិហារ | 17 | 45 | 18 | 120 | **200** | 10 | 7 | **17** | 73 | 14 | **87** |
| បន្ទាយមានជ័យ | 228 | 13 | 84 | - | **325** | 167 | 35 | **202** | 23 | 6 | **29** |
| សៀមរាប | 86 | 87 | 108 | 0 | **281** | 146 | 9 | **155** | 246 | 20 | **266** |
| កំពង់ឆ្នាំង | 1 | 21 | 1 | 0 | **23** | 60 | 0 | **60** | 6 | 0 | **6** |
| ប៉ៃលិន | 69 | 8 | 39 | 3 | **119** | 147 | 24 | **171** | 30 | 3 | **33** |
| បាត់ដំបង | 180 | 47 | 162 | 513 | **902** | 197 | 5 | **202** | 116 | 6 | **122** |
| ឧត្ដរមានជ័យ | 56 | 17 | 41 | - | **114** | 250 | 3 | **253** | 119 | 26 | **145** |
| ពោធិ៍សាត់ | 118 | 16 | 92 | 87 | **313** | 133 | 0 | **133** | 29 | 8 | **37** |
| កំពង់ស្ពឺ | 0 | 36 | 19 | 267 | **322** | 834 | 22 | **856** | 274 | 32 | **306** |
| ព្រះសីហនុ | 25 | 18 | 26 | - | **69** | 50 | 8 | **58** | 9 | 0 | **9** |
| តាកែវ | 155 | 7 | 38 | 2 | **202** | 410 | 155 | **565** | 87 | 25 | **112** |
| កំពត | 130 | 20 | 91 | 162 | **403** | 410 | 65 | **475** | 55 | 10 | **65** |
| កោះកុង | 2 | 30 | 122 | - | **154** | 153 | 3 | **156** | 68 | 0 | **68** |
| **សរុប** | 2070 | 834 | 1619 | 6725 | 11248 | 4519 | 1164 | 5683 | 2585 | 415 | 3000 |

## ៤. ការគាំទ្រផ្នែកសម្ភារៈ និងហិរញ្ញវត្ថុ

ចំពោះសមិទ្ធផលដែលសម្រេចបាននៅក្នុងការអនុវត្តយុទ្ធនាការដោះស្រាយការកកស្ទះសំណុំរឿង នៅតាមសាលាដំបូងរាជធានី ខេត្ត ក្នុងរយៈពេល ២២២ថ្ងៃកន្លងមកនេះ ក្រសួងយុត្តិធម៌បានទទួលការគាំទ្រផ្នែកសម្ភារៈ និងហិរញ្ញវត្ថុ ដែលជាកញ្ចប់ថវិការបស់រាជរដ្ឋាភិបាល ដោយចំណាយអស់ទឹកប្រាក់ប្រមាណ ២ពាន់លានរៀល។

## គ. សេចក្តីសន្និដ្ឋាន

### ១. លទ្ធផលសរុបរួម ២២២ ថ្ងៃនៃយុទ្ធនាការ

ជាលទ្ធផលសម្រាប់រយៈពេល ២២២ ថ្ងៃនៃយុទ្ធនាការ សំណុំរឿងព្រហ្មទណ្ឌកកស្ទះដែលបានចាត់ការរួច នៅតាមសាលាដំបូងរាជធានី ខេត្ត ទូទាំងប្រទេសទាំងដំណាក់កាលអយ្យការ ទាំងដំណាក់កាលស៊ើបសួរ និង ដំណាក់កាលជំនុំជម្រះ មានចំនួនសរុបប្រមាណ **៣៥.១០០ សំណុំរឿង ស្មើនឹង ៨៩%** នៃសំណុំរឿងព្រហ្មទណ្ឌ ដែលបានកកស្ទះកន្លងមក។ បន្ថែមពីនេះ សាលាដំបូងរាជធានី ខេត្តទូទាំងប្រទេស ក៏បានដោះស្រាយសំណុំរឿង ព្រហ្មទណ្ឌដែលចូលថ្មីចំនួនប្រមាណ **៣៦.៥០០ សំណុំរឿង ស្មើនឹង ៧៣%**។

### ២. ការរំពឹងទុក

ក្រៅពីសាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តទាំង១៥ ដែលបានទទួលជោគជ័យនៃការអនុវត្ត យុទ្ធនាការដោះស្រាយការកកស្ទះសំណុំរឿង មានសាលាដំបូងចំនួន ៩ ខេត្ត ដូចជាសាលាដំបូងរាជធានីភ្នំពេញ ខេត្ត កណ្តាល ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តកំពង់ធំ ខេត្តស្ទឹងត្រែង ខេត្តព្រះវិហារ ខេត្តកំពង់ឆ្នាំង និង ខេត្តព្រះសីហនុ ដែលអាចនឹងឈានដល់ការប្រកាសអំពីភាពជោគជ័យនៃការអនុវត្តយុទ្ធនាការដោះស្រាយការកកស្ទះសំណុំរឿងនា ពេលខាងមុខនេះ។

| សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី ខេត្ត ដែលរំពឹងថានឹងអាចប្រកាសជោគជ័យ | | | |
|---|---|---|---|
| ល.រ | សាលាដំបូង | ភាគរយនៃចំណាត់ការសំណុំរឿងចាស់ | ភាគរយនៃចំណាត់ការសំណុំរឿងថ្មី |
| ១ | រាជធានីភ្នំពេញ | 84% | 61% |
| ២ | កណ្តាល | 83% | 63% |
| ៣ | ព្រៃវែង | 87% | 62% |
| ៤ | ស្វាយរៀង | 95% | 64% |
| ៥ | កំពង់ធំ | 94% | 71% |
| ៦ | ស្ទឹងត្រែង | 96% | 64% |
| ៧ | ព្រះវិហារ | 92% | 73% |
| ៨ | កំពង់ឆ្នាំង | 92% | 67% |
| ៩ | ព្រះសីហនុ | 74% | 70% |

### ៣. ការវាយតម្លៃ

លទ្ធផលនៃយុទ្ធនាការនេះ កើតចេញពីកិច្ចខិតខំប្រឹងប្រែង និងសាមគ្គីផ្ទៃក្នុងរបស់សាលាដំបូង និង អយ្យការអមសាលាដំបូងទូទាំងប្រទេស និងតួអង្គដែលពាក់ព័ន្ធ ដែលបានប្តេជ្ញាចិត្ត ព្រមទាំងជម្នះនូវរាល់បញ្ហា

ប្រឈមនានាដើម្បីបុព្វហេតុ **«យុត្តិធម៌»** ។ ជាមួយគ្នានេះ លទ្ធផលជាវិជ្ជមាន សមិទ្ធផល និងសកម្មភាព ប្រកបដោយផ្លែផ្កានេះ ក៏បង្ហាញនូវសមត្ថភាពស្ថាប័នក្នុងការផ្ដល់ និងធ្វើឱ្យកាន់តែប្រសើរឡើង នូវការផ្ដល់សេវាយុត្តិធម៌ ជូនប្រជាពលរដ្ឋ ស្របតាមគោលនយោបាយកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងការពង្រឹងនីតិរដ្ឋនៅព្រះរាជាណាចក្រកម្ពុជា បើទោះបីជាពុំមានដៃគូអភិវឌ្ឍន៍ ឬសហប្រតិបត្តិការអន្តរជាតិណាមួយ ចូលរួមចំណែកគាំទ្រដល់យុទ្ធនាការនេះក៏ដោយ។

ថ្ងៃពុធ ១រោច ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ ២០២០

**លេខាធិការដ្ឋាននៃ គ.ឃ.ក.ស.**

**ប្រធាន**

K. Rith

**កើត សុម៉ារិទ្ធ**